**និយ័តករបរធនបាលកិច្ច**

**TRUST REGULATOR**

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កម្មវិធីបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រី "ភាពជាអ្នកដឹកនាំ៖ ជវភាព, ភាពរស់រវើក, តុល្យភាព"

ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២

នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) សហការជាមួយនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល និងកសាងសមត្ថភាពមន្ត្រី ស្តីពី "ភាពជាអ្នកដឹកនាំ÷ ជវភាព, ភាពរស់រវើក, តុល្យភាព" ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹង និងបង្កើនសមត្ថភាព ក៏ដូចជាទទួលបាននូវចំណេះដឹង និងបទពិសោធន៍បន្ថែមទៀតពាក់ព័ន្ធភាពជាអ្នកដឹកនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **ន.ប.ធ.** និង **ន.ម.ក.** សរុបប្រមាណ ១៥០នាក់ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

សិក្ខាសាលានេះ មានការចូលរួមពីវាគ្មិនកិត្តិយស រួមមាន÷ ឯកឧត្តមបណ្ឌិត **ហួត ពុំ** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិកាដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃ **ន.ម.ក.** និង ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ដែលបានធ្វើបទបង្ហាញ និងពិភាក្សាលើប្រធានបទភាពជាអ្នកដឹកនាំសម្រាប់ខ្លួនឯង ភាពជាអ្នកដឹកនាំសម្រាប់ស្ថាប័ន និងបទពិសោធន៍អនុវត្តន៍ភាពជាអ្នកដឹកនាំពីប្រទេសសិង្ហបុរី ហើយត្រូវបានចូលរួមយ៉ាងសកម្ម និងផុសផុលពីសិក្ខាកាម ព្រមទាំងបានបញ្ចប់ប្រកបដោយផ្លែផ្កាខ្ពស់។